| រឿងផ្លាស់ប្តូរលេចធ្លោ នៅសង្កាត់ វត្តគរ | |
| --- | --- |
|  | |
| ឈ្មោះកម្មវិធី | គម្រោង PROCEED |
| ចំណងជើងរឿង | **កសាងទំនុកចិត្ត ដើម្បីសហគមន៍** |
| កាលបរិច្ឆេទនៃការកត់ត្រា | ១៥ មីនា ២០១៥ |
| រឿងនោះកើតឡើងនៅពេលណា | ឆ្នាំ ២០១៣ ដល់ ២០១៥ |
| ឈ្មោះភូមិ ឬស្រុក (ទីកន្លែងដែលរឿងបានកើតឡើង) | ភូមិដំណាក់ហ្លួង សង្កាត់វត្តគរ ក្រុងបាត់ដំបង |
| ឈ្មោះអ្នកនិយាយរឿងប្រាប់ | អ្នកស្រី **ប៉ា សុខខេង** ប្រធានសហគមន៍តស៊ូដើម្បីអភិវឌ្ឍន៍ សង្កាត់វត្តគរ ក្រុងបាត់ដំបង |
| ចំនួនអ្នកទទួលផល (ជាក្រុម) ដែលទទួលផលពីសកម្មភាព របស់បុគ្គលដែលផ្តល់រឿង | ប្រជាពលរដ្ឋក្នុងភូមិ ដំណាក់ហ្លួង សង្កាត់វត្តគរ ក្រុងខេត្តបាត់ដំបង |
| -អាយុជាមធ្យម (បុរស ឬស្ត្រី) | អាយុ ៥៤ ឆ្នាំ |
| អ្នកសម្ភាសន៍(តួនាទី, អង្គភាព) | លោក **ប៉ៅ សចិន** បុគ្គលិកអង្គការ អមរា |
| អ្នកកត់ត្រា(តួនាទី, អង្គភាព) | អ្នកស្រី **ថុខ មួយលី** បុគ្គលិកអង្គការ អមរា |

# ពិពណ៌នារឿង



អ្នកស្រី **ប៉ា សុខខេង** អាយុ៥៤ឆ្នាំ នៅភូមិដំណាក់ហ្លួង សង្កាត់វត្តគរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។ អ្នកស្រីបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៨ចាស់ នៃសាលាបឋមសិក្សាស្ទឹង ។ អ្នកស្រីជាប្រធានសហគមន៍តស៊ូ ដើម្បីអភិវឌ្ឍន៍ចាប់តាំងពីឆ្នាំ២០១២ នៅភូមិដំណាក់ហ្លួង សង្កាត់វត្តគរ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។ ទោះបីពេលនេះលោកស្រីជាប្រធានសហគមន៍ក៏ដោយប៉ុន្តែ អ្នកស្រីមានក្តីកង្វល់ជាខ្លាំងក្នុងការបំពេញការងារជូនសហគមន៍ឲ្យទទួលបានជោគជ័យ ព្រោះអ្នកស្រីមានអារម្មណ៍ថាខ្លួនឯងមិនមានចំណេះដឹង និងបទពិសោធន៍ជ្រៅជ្រះ ផ្នែកការងារសង្គម និងការអភិវឌ្ឍសហគមន៍ ។ លើសពីនោះទៀត អ្នកស្រីមិនមានទំនុកចិត្ត ក្នុងការនិយាយជាមួយសហគមន៍ និងមិនមានភាពក្លាហានក្នុងការទំនាក់ទំនងជាមួយក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងក្រុងបាត់ដំបង ដោយសារមានភាពភ័យខ្លាច និងមានការស្ទាក់ស្ទើក្នុងការចូលរួម និងបញ្ចេញមតិយោបល់ចំពោះមុខអាជ្ញាធរមូលដ្ឋាន ។

ក្នុងឆ្នាំ២០១៣ អ្នកស្រីត្រូវបានជ្រើសរើសជាដៃគូដើម្បីអនុវត្ត *"គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ"* (PROCEED) ជាមួយអង្គការអមរា ។ ក្នុងអំឡុងពេលចូលរួមជាមួយគម្រោង PROCEED អ្នកស្រី **ប៉ា សុខខេង** បានទទួលនូវការបណ្តុះបណ្តាល និងការបង្ហាត់បង្ហាញ ជាច្រើនពីការចូលរួមក្នុងសកម្មភាពអភិវឌ្ឍនានារបស់ក្រុមប្រឹក្សាសង្កាត់ ការកៀរគរឲមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាតាមមូលដ្ឋាន ការលើកបញ្ហាតម្រូវការក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ទស្សនទាននៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ជំនាញសម្របសម្រួលសហគមន៍ ជំនាញនិយាយសាធារណៈ សិទ្ធិជាមូលដ្ឋាន អភិបាលកិច្ចល្អមូលដ្ឋាន ការលើកកម្ពស់ការចូលរួមរបស់ស្រ្តី តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង សង្កាត់ តួនាទីរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ការផ្សារភ្ជាប់ទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយនឹងប្រជាពលរដ្ឋ គណនេយ្យភាពសង្គម និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពរបស់ក្រុមប្រឹក្សាជាដើម ។



តាមរយៈនៃការចូលរួមជាមួយគម្រោង PROCEED អ្នកស្រីមានទំនុកចិត្តថា ***ខ្លួនឯងពុំមានការភ័យខ្លាច*** ដូចមុនទៀតឡើយ ។ អ្នកស្រីបានចូលរួមបញ្ចេញមតិយោបល់ជាមួយប្រជាពលរដ្ឋ និងជា

| |
|---|
| **ការអង្កេតលើចំនុចសំខាន់ៗ៖ កាយវិការ អារម្មណ៍ អត្តចរិត របស់អ្នកទទួលសម្ភាសន៍**<br><br>អ្នកស្រី **ប៉ា សុខខេង** និយាយបណ្តើរញញឹមបណ្តើរ *(ខ្ញុំមានមោទនភាពបំផុតចំពោះខ្លួនឯង និងសប្បាយចិត្ត ដែលប្រជាពលរដ្ឋស្រឡាញ់ពេញចិត្តខ្ញុំ ហើយក្រុមប្រឹក្សាទទួល ស្គាល់ខ្ញុំ និងជឿជាក់លើការលះបង់របស់ខ្ញុំ ដូច្នេះ ខ្ញុំនឹងបន្តជួយសង្គម និងចូលរួមបំរើផលប្រយោជន៍រួមក្នុងសហគមន៍ )*។ |
| **ផ្នែកផ្លាស់ប្តូ** (Domain of changes)<br><br>អភិបាលកិច្ចល្អ |